# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:.២០.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

### សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិ នៃកងយោធពលខេមរភូមិន្ទ ដែលមាន ៣ (បី)ថ្នាក់ ស្ថិតក្រោមការគ្រប់គ្រង ដឹកនាំផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ។

ក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិមានប្រធាន១ (មួយ)រូប និងអនុប្រធាន ព្រមទាំងសមាជិកមួយចំនួន។

ក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិត្រូវបង្កើតលេខាធិការដ្ឋានរបស់ខ្លួន សម្រាប់ជួយក្នុងការបំពេញភារកិច្ច។

រចនាសម្ព័ន្ធចាត់តាំងរបស់ក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងការពារជាតិ។

**មាត្រា២.-**

ក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិត្រូវបង្កើតឡើងជា ៣ (បី)ថ្នាក់ដូចខាងក្រោម៖

**ក- ថ្នាក់ក្រសួងការពារជាតិ**

សមាសភាពដែលចាត់តាំងចូលក្នុងក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់មាន៖

អតីតប្រធានអគ្គសេនាធិការ ឬអគ្គមេបញ្ជាការ អគ្គលេខាធិការ អគ្គនាយក សាកលវិទ្យាធិការ អគ្គមេបញ្ជាការរងនាយសេនាធិការចម្រុះ មេបញ្ជាការប្រភេទទ័ព មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងមេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស មានឋានៈស្មើនឹងរដ្ឋមន្ត្រី។

**ខ- ថ្នាក់អគ្គបញ្ជាការដ្ឋាន**

សមាសភាពដែលចាត់តាំងចូលក្នុងក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់មាន៖

អតីតមេបញ្ជាការយោធភូមិភាគ មេបញ្ជាការរងនាយសេនាធិការប្រភេទទ័ព នាយកវិទ្យាស្ថាន នាយកសាលានាយទាហានសកម្ម នាយកមន្ទីរពេទ្យព្រះកេតុមាលា មេបញ្ជាការរងនាយសេនាធិការបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការរងនាយសេនាធិការបញ្ជាការដ្ឋានអង្គរក្ស មេបញ្ជាការមូលដ្ឋានសមុទ្រ មេបញ្ជាការមូលដ្ឋានទ័ពអាកាសពោធិ៍ចិនតុង មេបញ្ជាការបញ្ជាការដ្ឋានការពារកោះ-ឆ្នេរ មេបញ្ជាការបញ្ជាការដ្ឋានចំណុះអគ្គបញ្ជាការ និងមេបញ្ជាការកងពលធំ មានឋានៈស្មើនឹងរដ្ឋលេខាធិការ។

**គ- ថ្នាក់ប្រភេទទ័ព**

សមាសភាពដែលចាត់តាំងចូលក្នុងក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់មាន៖

អតីតមេបញ្ជាការរងនាយសេនាធិការយោធភូមិភាគ មេបញ្ជាការកងពលតូច មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថរាជធានី/ខេត្ត នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺននៃប្រភេទទ័ពនិងទ័ពជំនាញ មេបញ្ជាការបញ្ជាការដ្ឋានទ័ពជំនាញចំណុះកងទ័ពជើងគោក នាយកសាលាពលទាហានចំណុះយោធភូមិភាគ មានឋានៈស្មើនឹងអនុរដ្ឋលេខាធិការ។

**មាត្រា៣.-**

ក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវស្វែងយល់ដោយផ្ទាល់ក្នុងស្ថាប័ន អង្គភាពនៃកងយោធពលខេមរភូមិន្ទ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអំពីកិច្ចការជាយុទ្ធសាស្ត្រវិស័យការពារជាតិ
- ពិគ្រោះ និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ និងមេបញ្ជាការប្រភេទទ័ព នូវគោលគំនិតយុទ្ធសាស្ត្រ និងវិធានការចាត់តាំងអនុវត្តតាមការវិវត្តន៍ជាក់ស្តែង នៃសភាពការណ៍បច្ចុប្បន្ន ព្រមទាំងទស្សនទាននៅពេលខាងមុខ បម្រើឱ្យចក្ខុវិស័យយុទ្ធសាស្ត្ររយៈវែង
- រួមចំណែកកសាង កែលម្អរាល់ឯកសារគតិយុត្តក្នុងវិស័យការពារជាតិ
- រួមចំណែកពិគ្រោះ និងផ្តល់យោបល់នៅតាមថ្នាក់ នូវកិច្ចការជាយុទ្ធសាស្ត្រ កិច្ចការក្នុងកម្រិតយុទ្ធនាការនៃកម្រិតយុទ្ធវិធីតាមជំនាញ និងប្រភេទទ័ព
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជាក់ស្តែងរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ និងមេបញ្ជាការប្រភេទទ័ព។

**មាត្រា៤.-**

សមាសភាពសមាជិកក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ក្នុងកិច្ចការការពារជាតិត្រូវមានលក្ខណសម្បត្តិជានាយទាហានដូចខាងក្រោម៖

- ជាយោធិនចូលនិវត្តន៍បានបម្រើការងារក្នុងកងទ័ពយ៉ាងតិច ៣០(សាមសិប)ឆ្នាំ
- ធ្លាប់បានបំពេញមុខងារគ្រប់គ្រងដឹកនាំបញ្ជាស្ថាប័ន អង្គភាពកងទ័ពដែលបានកំណត់ក្នុងមាត្រា២
- ត្រូវបានស្នើឡើងតាមឋានានុក្រម តាមថ្នាក់ ដូចបានកំណត់ក្នុងមាត្រា២។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៣ រោច ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ